អគ្គនាយកដ្ឋានរដ្ឋបាល
ក្រុមការងារព័ត៌មានវិទ្យា

# អនុស្សរណៈ នៃការយោគយល់
## រវាង
## រាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការដាក់បញ្ចូលច្រកព្រំដែន នៅព្រែកចាក/លក(ព្រះរាជាណាចក្រកម្ពុជា) និង សាសៀវ(សាធារណរដ្ឋសង្គមនិយមវៀតណាម) និង តំរាយផ្លូវតាមបណ្តោយតំបន់ សាសៀ-ហាទៀន-គៀនលួង-រ៉ាច់ហ្សាយ-កាម៉ាវ-ណាំកាន ទៅក្នុងពិធីសារទី១ នៃកិច្ចព្រមព្រៀង រវាង និងក្នុងរង្វង់រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីអំពីការសំរបសំរួលនូវការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន

រាជរដ្ឋាភិបាលកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម(តទៅហៅកាត់ថា" ភាគីចុះកិច្ចសន្យានៃអនុស្សារណៈ" )

**យោង**កិច្ចព្រមព្រៀងរវាងនិងក្នុងរង្វង់រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជាសាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីអំពីការសំរបសំរួលនូវការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ដែលបានចុះហត្ថលេខាតំបូង នៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ នៅវៀងច័ន្ទ និងធ្វើវិសោធនកម្ម នៅថ្ងៃទី ២៩ វិច្ឆិកា ឆ្នាំ ២០០១ នៅយ៉ាងហ្គូន . ដែលបានយល់ព្រមចូល ដោយព្រះរាជាណាចក្រកម្ពុជា នៅយ៉ាងហ្គូន នៅថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០០១ បានយល់ព្រមចូល ដោយសាធារណរដ្ឋប្រជាមានិតចិន នៅថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ ២០០២ នៅភ្នំពេញ និងបានយល់ព្រមចូល ដោយសហភាពមីយ៉ាន់ម៉ា នៅថ្ងៃ ១៩ ខែកញ្ញា ឆ្នាំ ២០០៣ នៅទីក្រុងដាលី តទៅហៅកាត់ថា " កិច្ចព្រមព្រៀង" ។

**ទទួលស្គាល់ថា** កិច្ចព្រមព្រៀងបានចូលជាធរមាន កាលពីថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៣ ដោយមានការតំកល់ទុក សច្ចាប័ន/ការយល់ព្រមចូល ដោយភាគីទាំងប្រាំមួយនៃកិច្ចព្រមព្រៀង ។

**យោង**មាត្រា២ ក្នុងពិធីសារទី១ នៃកិច្ចព្រមព្រៀង ស្តីការកំណត់ផ្លូវរបៀង និងផ្លូវ ព្រមទាំងចំណុចចូល-ចេញ(ការឆ្លងកាត់ព្រំដែន) ដែលបានចែងអំពីនីតិវិធី ក្នុងការបើកបន្ថែម ច្រកឆ្លងកាត់ព្រំដែន និងផ្លូវទាំងឡាយ ដែលអនុវត្តចំពោះកិច្ចព្រមព្រៀង។

**យោង** សេចក្តីប្រកាសនៃកិច្ចប្រជុំកំពូលលើកទី២ របស់ថ្នាក់ដឹកនាំកំពូលនៃប្រទេសមហាអនុតំបន់ទន្លេ មេគង្គ ដែលបានប្រព្រឹត្តទៅនៅទីក្រុងគុនមីង សាធារណរដ្ឋប្រជាមានិតចិន នៅថ្ងៃទី ៤-៥ ខែកក្កដា ឆ្នាំ ២០០៥ ដែល ស្នើឱ្យរដ្ឋមន្ត្រីពាក់ព័ន្ធទាំងឡាយ នៅក្នុងប្រទេសមហាអនុតំបន់ទន្លេមេគង្គ ជំរុញឱ្យបានលឿន និងបំណងអនុវត្តកិច្ចព្រម ព្រៀង ដោយការបង្កើនបន្ថែមឱ្យបានច្រើនច្រកឆ្លងកាត់ព្រំដែន។

**បានព្រមព្រៀងគ្នាដូចខាងក្រោម :**

**មាត្រា១.- ការដាក់បញ្ចូល ព្រែកចាក/លក-សាសៀវ និងតំរាយផ្លូវតាមបណ្តោយតំបន់ សាសៀ-ហាទៀន-គៀនលួង-រ៉ាច់ហ្សាយ-កាម៉ាវ-ណាំកាន ទៅក្នុងពិធីសារទី១ នៃកិច្ចព្រមព្រៀង :**

ភាគីនៃអនុស្សារណៈ ត្រូវបើកច្រកឆ្លងកាត់ព្រំដែនរបស់ខ្លួននៅ ព្រែកចាក/លក-សាសៀវ និងតំរាយផ្លូវដែលស្ថិតនៅ ក្នុងសាធារណរដ្ឋសង្គមនិយមវៀតណាម តាមបណ្តោយតំបន់សាសៀ-ហាទៀន -គៀនលួង-រ៉ាច់ហ្សា-កាម៉ាវ-ណាំកាន ឱ្យទៅជាច្រក និងតំរាយផ្លូវឆ្លងកាត់ ព្រំដែនថ្មីមួយ ដែលអនុវត្តដោយកិច្ចព្រមព្រៀង។

## ឯកសារភ្ជាប់ទី១ : តារាងបញ្ជីរ នៃការកំនត់ផ្លូវរបៀង, ផ្លូវថ្នល់ ហើយនិងច្រកឆ្លងកាត់ព្រំដែននៃពិធីសារទី១

### ១-របៀងសេដ្ឋកិច្ច ខាងជើង — ខាងត្បូង

a) ច្រកផ្លូវ : គុនមិញ-យូស៊ី-យូនជាំង-មូហ៊ី-ស៊ីម៉ៅ-ស៊ីអូមីនយាង-មូហាន (ចិន) បូទីន-ហួយសាយ(ឡាវ) ឆៀងខុង-ឆៀងរៃ-តាក-បាងកក(ថៃ)

(I) ច្រកឆ្លងកាត់ព្រំដែន :មូហាន (ចិន) - បូទិន (ឡាវ)

(II) ច្រកឆ្លងកាត់ព្រំដែន : ហួយសាយ(ឡាវ) - ឆៀងខុង(ថៃ)

b) ច្រកផ្លូវ : គីងតុង តាជីលេក(មីយ៉ាន់មា) - មេសៃ - ឆៀងរ៉ៃ - តាក - បាងកក(ថៃ)

(I) ច្រកឆ្លងកាត់ព្រំដែន : តាជិលិក(មីយ៉ាន់មា) - មេសៃ(ថៃ)

c) ច្រកផ្លូវ : គុនមិញ-មៃលី-យីនសាវ - កៃយូន មេងស៊ុ - ហេគូ(ចិន)-ឡាវកៃ-ហាណូយ-ហៃហ្វុង (វៀតណាម) ។

(I) ច្រកឆ្លងកាត់ព្រំដែន : ហេគូ(ចិន)-ឡាវកៃ(វៀតណាម)

### ២-របៀងសេដ្ឋកិច្ច ខាងកើត - ខាងលិច

a) ច្រកផ្លូវ : ម៉ាវឡាមៀន-មីយ៉ាវ៉ាឌី(មីយ៉ានម៉ា)-មេសត-ពិស្ណុលោក-ខនខៀន-កាឡាស៊ីន -មូកដាហាន(ថៃ)-សាវ៉ាន់ណាខេត្ត-ដានសាវ៉ាញ់(ឡាវ)-ឡាវបៅ-ដុងហា-វ៉េ-ដាណាង(វៀតណាម)

(I) ច្រកឆ្លងកាត់ព្រំដែន : មីយ៉ាវ៉ាឌី(មីយ៉ាន់ម៉ា)-មេសត(ថៃ)

(II) ច្រកឆ្លងកាត់ព្រំដែន : ម៉ុកដាហាន(ថៃ)-សាវ៉ាន់ណាខេត្ត(ឡាវ)

(III) ច្រកឆ្លងកាត់ព្រំដែន : ដានសាវ៉ាញ់(ឡាវ)-ឡាវបៅ(វៀតណាម)

### ៣-របៀងសេដ្ឋកិច្ច ប៉ែកខាងត្បូង

a) ច្រកផ្លូវ : បាងកក-កាបីនបូរី-ស្រះកែវ-អារញ្ញប្រាថេទ
ឬ បាងកក-លៀមចាបាង-ភ្នំសារាខាំ-កាបីនបូរី-ស្រះកែវ-អរញ្ញប្រាថេទ"(ថៃ)>-បោយប៉ែត-ស៊ីសុផុន ពោធិសាត់- ភ្នំពេញ-អ្នកលឿង-បាវិត(កម្ពុជា)-ម៉ុកបៃ-ទីក្រុងហូជីមិញ-វង់តាវ(វៀតណាម)

(I) ច្រកឆ្លងកាត់ព្រំដែន : អរញ្ញប្រាថេទ"(ថៃ)-បោយប៉ែត(កម្ពុជា)

(II) ច្រកឆ្លងកាត់ព្រំដែន :បាវិត(កម្ពុជា)-ម៉ុកបៃ(វៀតណាម)

b) [ច្រកផ្លូវ : បាងកក-ត្រាត-ហាតលេក(ថៃ)-ចាំយាម-កោះកុង-ស្រែអំបិល-កំពត-លក(កម្ពុជា) -ហាទៀន-កាមូ-ណាមខេន(វៀតណាម)]

(I) ច្រកឆ្លងកាត់ព្រំដែន : ហាតលេក(ថៃ)-ចាំយាម(កម្ពុជា)

(II) ច្រកឆ្លងកាត់ព្រំដែន : **ព្រែកចាក/លក(កម្ពុជា) - -សាសៀវ(វៀតណាម)-ហាទៀន -គៀនលួង - រ៉ាច់ហ្សា-កាម៉ាវ-ណាំកាន**

### ៤-ផ្លូវរបៀងធំ, ផ្លូវថ្នល់, និងច្រកឆ្លងកាត់ព្រំដែនផ្សេងទៀត

a) ច្រកផ្លូវ : គូនមិញ-ចូសុង-ដាលី-បៅហ្សាន-រូលី(ចិន)-មូសេ-ឡាសៅ(មីយ៉ាន់ម៉ា)

(I) ច្រកកាត់ព្រំដែន : រូលី(ចិន)-មូសេ(មីយ៉ាន់ម៉ា)

b) ច្រកផ្លូវ : វៀងច័ន្ទ-បានឡាវ-ថាកហិក-សិន្ទូ-ផាកសេ(ឡាវ)-ឡាវ/ព្រំដែនកម្ពុជា(វ៉ឺនខាំ)-ស្ទឹងត្រែង-ក្រចេះ-ភ្នំពេញ-ក្រុងព្រះសីហនុ(កម្ពុជា) ។

(I) ច្រកឆ្លងកាត់ព្រំដែន :វ៉ឺនខាំ(ឡាវ), ដុងក្រឡ(កម្ពុជា)

c) ច្រកផ្លូវ : ណាទើយ-ឧត្តមសៃ-ផាកមុង-លួងប្រាបាង-វៀងច័ន្ទ-ថាណាឡេង(ឡាវ)-នងខៃ-ឧដុនថានី-ខុនកៀន-បាងកក(ថៃ)

(I) ច្រកឆ្លងកាត់ព្រំដែន : ថាណាឡេង(ឡាវ) - នងខៃ(ថៃ)

d) ច្រកផ្លូវ : វៀងច័ន្ទ-បូលីខាមសាយ(ឡាវ)-ហាទិញ(វៀតណាម)

(I) ច្រកឆ្លងកាត់ព្រំដែន : ណាម ផៅ(ឡាវ)-កៅត្រូ(វៀតណាម)

e) [ច្រកផ្លូវ :ចំប៉ាសាក់(ឡាវ)-ឧប្បលរាជធានី(ថៃ)]

(I) ច្រកឆ្លងកាត់ព្រំដែន : វ៉ាំងតៅ(ឡាវ)-ចុងមេក(ថៃ)

**មាត្រា២.- ការជូនដំណឹងទៅគណៈកម្មាធិការរួម និងការធ្វើវិសោធនកម្ម ពិធីសារទី១ :**

ដោយអនុលោមតាមមាត្រា២ ក្នុងពិធីសារទី១ នៃកិច្ចព្រមព្រៀង ភាគីចុះកិច្ចសន្យានៃអនុស្សារណៈ ត្រូវជូនដំណឹងជាបន្ទាន់ជូនទៅគណៈកម្មការរួម នូវការដាក់បញ្ចូលច្រកឆ្លងកាត់ព្រំដែននៅ លក-សាសៀវ និង តំរាយផ្លូវដែលស្ថិតនៅក្នុងសាធារណរដ្ឋសង្គមនិយមវៀតណាម តាមបណ្ដោយតំបន់សាសៀ-ហាទៀន -គៀនលូង -រ៉ាច់ហ្យា-កាម៉ាវ-ណាំកាន និងផ្ដួចផ្ដើមធ្វើវិសោធនកម្មមួយនៃពិធីសារទី១ នៃកិច្ចព្រមព្រៀង សំរាប់ គោលបំណងនេះ ។

**មាត្រា៣.- ការបើកច្រកឆ្លងកាត់ព្រំដែន និងតំរាយផ្លូវថ្មី**

ច្រកឆ្លងកាត់ព្រំដែន នៅ ព្រែកចាក/លក-សាសៀវ និង តំរាយផ្លូវដែលស្ថិតនៅក្នុងសាធារណរដ្ឋសង្គមនិយមវៀតណាម តាមបណ្ដោយតំបន់សាសៀ-ហាទៀន -គៀនលូង -រ៉ាច់ហ្យា-កាម៉ាវ-ណាំកាន អាចត្រូវបើកឡើងបាននៅក្រោយពេលដែលមានការតំកល់ទុកការយល់ព្រម ឬសច្ចាប័ន នៃការធ្វើវិសោធនកម្មពិធីសារទី១ ដូចមានចែងនៅក្នុងមាត្រា២ នៃអនុស្សារណៈនេះ។ ច្រកឆ្លងកាត់ព្រំដែន និងតំរាយផ្លូវថ្មីបន្ថែមនេះ ត្រូវមានលក្ខខ័ណអនុវត្តដូចគ្នា ទៅនឹងផ្លូវតំបូងៗទាំងឡាយក្នុងពិធីសារទី១ នៃកិច្ចព្រមព្រៀង។

**មាត្រា៤.- ការចូលជាធរមាន នៃអនុស្សារណៈ**

អនុស្សារណៈនេះ ត្រូវចូលជាធរមាន បន្ទាប់ពីពេលចុះហត្ថលេខានេះតទៅ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១២ ខែកុម្ភៈ .ឆ្នាំ ២០០៧ ជា០២ ច្បាប់ដើម ជាភាសាអង់គ្លេស ។

**ហត្ថលេខា :**

**តំណាងរាជរដ្ឋាភិបាលកម្ពុជា**

ឯកឧត្តម **ស៊ុន ចាន់ថុល** រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន

**តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម**

ឯកឧត្តម **ហូ ងា ហ៊្វឹង** រដ្ឋមន្ត្រីដឹកជញ្ជូន